# អ្នកនាំសារ

## The Messenger

20

ខែ កុម្ភៈ ឆ្នាំ ២០០៥- ព័ត៌មានពីព្រះសហគមន៍កាតូលិក



ពិធីបុណ្យចូលឆ្នាំ
ចិន-វៀតណាម

# សួស្តីឆ្នាំថ្មី! ឆ្នាំរកា!



តើសាសនាឆ្លើយ
តបបានអ្វីខ្លះដល់យុវ
ជន?
ទំព័រ ២



ថ្ងៃនៃសេចក្តី
ស្រលាញ់
Valentine's day
ទំព័រ ៥

ឆ្នាំរកា! ទាម
ទារឱ្យមានការ
ព្យាយាម
ទំព័រ ៦

# តើសាសនាឆ្លើយតបបានអ្វីខ្លះដល់យុវជន?

សព្វថ្ងៃ សង្គមកម្ពុជាកំពុងមានការវិវត្តន៍ទៅរកទាំងផ្លូវវិជ្ជមាន និងផ្លូវអវិជ្ជមាន។ អ្វីដែលគួរបារម្ភបំផុតនោះ គឺយុវជនភាគច្រើនកំពុងប្រឈមមុខ នឹងបញ្ហាសង្គម មានដូចជា កង្វះការអប់រំ ភាពគ្មានការងារធ្វើ កំណើនបទល្មើស និងក្រុមបងធំ។ សំរាប់បញ្ហាទាំងនេះ តើសាសនានៅក្នុងប្រទេសកម្ពុជាអាចឆ្លើយតបបានអ្វីខ្លះ?



## សាសនាជាជំនួយផ្លូវចិត្ត

សាសនាទាំងឡាយ ដែលមានចំណាស់មុនសម័យសង្គ្រាមនៅក្នុងប្រទេសកម្ពុជាកំពុងរស់ឡើងជាថ្មីម្តងទៀត។ “ពុទ្ធមណ្ឌលធម្មទូត” ដែលស្ថិតនៅក្នុងស្រុកកៀនស្វាយខេត្តកណ្តាលទើបត្រូវបានសម្ពោធដាក់ឱ្យប្រើប្រាស់ កាលពីពាក់កណ្តាលខែមករា។ នេះជាសញ្ញាបញ្ជាក់អំពីការពង្រឹងផ្នែកអប់រំ និងការផ្សព្វផ្សាយចំណេះដឹងដល់យុវជន។ ព្រះភិក្ខុ យឺន បញ្ញាវណ្ណ មានជំនឿយ៉ាងមុតមាំថា យុវជននឹងកាន់តែជឿសាសនាច្រើនតាមរយៈការមកទស្សនាពុទ្ធមណ្ឌលនេះ។ ព្រះអង្គពន្យល់ថា: “យើងផ្តោតជាសំខាន់សំរាប់ការធ្វើសមាធិ។ យើងអាចផ្តល់ជាជំនួយផ្លូវចិត្តដល់ពួកគេដែលមានបញ្ហាស្មុគស្មាញក្នុងអារម្មណ៍ ឬបញ្ហាលំបាកណាមួយក្នុងសង្គមគ្រួសារ និងការងារ”។ លោកឪពុក Mario អ្នកទទួលខុសត្រូវព្រះសហគមន៍បឹងទំពុន ហើយនិងបង្រៀននៅឯទេវវិទ្យាល័យបញ្ជាក់ថា: “យុវជនត្រូវតែត្រៀមខ្លួនអប់រំខ្លួនជាមុនសិនដើម្បីអាចជួយណែនាំអ្នកដទៃបាន។ ការអប់រំផ្លូវចិត្ត គឺជាការធ្វើខ្លួនទៅជាមនុស្សសុចរិត និងចេះស្រលាញ់គ្នាទៅមកជាដើម”។

## ការចូលរួមក្នុងកិច្ចការសង្គមនៅមានកំរិត

ព្រះភិក្ខុ យស ហ៊ុត ខេមចារោ យល់ថា ដើម្បីឱ្យសាសនាអាចចូលរួមដោះស្រាយបញ្ហាយុវជនក្នុងសង្គមបាន មានតែធ្វើការអប់រំអ្នកចេះដឹងឱ្យបានជាមុនសិន។ កិច្ចការនេះត្រូវការពេលវេលាយូរដើម្បីកសាងនូវធនធានមនុស្ស។ គួររំលឹកថា



Photo: Kuy Ven

ពុទ្ធមណ្ឌលធម្មទូតដែលសាងសង់ក្នុងស្រុកកៀនស្វាយខេត្តកណ្តាល ឆ្វេង:ព្រះវិហារតាហែននៅបាត់ដំបង

ការចូលរួមបច្ចុប្បន្ននេះ របស់ព្រះពុទ្ធសាសាមានតែតាមរយៈប្រព័ន្ធផ្សព្វផ្សាយប៉ុណ្ណោះ។ ចំនែកសកម្មភាពជាក់ស្តែង មានដូចជាការចូលរួមក្នុងយុទ្ធនាការបង្ការជំងឺអេដស៍ ការកាត់បន្ថយអាវុធជាតិផ្ទុះគ្រឿងញៀន និងការអប់រំសិទ្ធិមនុស្ស ពុំមានលក្ខណៈដែលធ្វើជាប់ជាប្រចាំឡើយ។

ចំណែកជំនួយរបស់ព្រះសហគមន៍កាតូលិកទៅឱ្យសង្គមក៏នៅមានកំរិតនៅឡើយដែរ។ យុវជនកាតូលិកខ្មែរតែងតែបានទទួលនូវអាហារូបករណ៍សិក្សានៅតាមមហាវិទ្យាល័យនាទីក្រុងភ្នំពេញ។ ខណ:ពេលដែលសាសនាខាងលើ នៅមានព្រំដែនរបស់ខ្លួន សាសនាឥស្លាមក៏ស្ថិតក្នុងស្ថានភាពដូចគ្នានេះផងដែរ។ លោកឧកញ៉ា សុះ កស៊ី ចាងហ្វាងនៃគណ:ដឹកនាំជាន់ខ្ពស់នៃសាសនាឥស្លាមកម្ពុជាបានមានប្រសាសន៍ថា: “សព្វថ្ងៃនេះ យើងមានកំរិតនៅឡើយដោយសារមកពីភាពក្រីក្រ និងខ្វះធនធានមនុស្ស។ យើងកំពុងឱ្យប្រទេសឥស្លាមម្ចាស់ជំនួយជួយដល់ជីវភាពប្រជាជន ជាជាងការពង្រីកជំនឿសាសនា”។ ថ្មីៗនេះ ក្រោយពីមានការអនុញ្ញាតរបស់រដ្ឋាភិបាល “សហគមន៍ជ្រោយមេត្រី” បានគ្រោងបង្កើតជាមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវ:ដល់យុវជនខ្មែរឥស្លាម។

## កសាងមូលដ្ឋានគ្រឹះតាមរយ:ការអប់រំ

ដោយយល់ឃើញថាការអប់រំ គឺជាសសរស្តម្ភចាំបាច់ដើម្បីពង្រឹងជំនឿ ក៏ដូចជាផ្លូវចិត្តប្រជាជន។ ក្នុងនោះ ទេវវិទ្យាល័យ សន្ត យ៉ូហាន ម៉ារី វីយ៉ាណែ បានធ្វើការបណ្តុះបណ្តាលយុវជនឱ្យក្លាយជាបូជាចារ្យជួយអប់រំជំនឿនិងចូលរួមអភិវឌ្ឍន៍ព្រះសហគមន៍ផងដែរ។ ផ្សារភ្ជាប់ជាមួយនឹងទស្សនវិស័យនេះផងដែរ ព្រះពុទ្ធសាសនាក៏មានប្រព័ន្ធអប់រំព្រះសង្ឃ តាំងពីថ្នាក់សាលាធម្មវិន័យរហូត

### ចំនួនគ្រិស្តបរិស័ទកាតូលិកនៅកម្ពុជា

គ្រិស្តបរិស័ទព្រះសហគមន៍កាតូលិកមានប្រហែលជា៣០០០០នាក់ ភាគច្រើនជាជនជាតិវៀត-ណាមដែលរស់នៅក្នុងប្រទេសកម្ពុជា។ អ្នកដែលកំពុងស្វែងយល់ព្រះបន្ទូលព្រះយេស៊ូគ្រិស្តមានចំនួន១៣២៦នាក់ដោយចែកជា៤ក្រុមគឺ ក្រុមអ្នកស្វែងរកចំនួន៥៩៥នាក់ ក្រុមត្រៀមចូលព្រះសហគមន៍ចំនួន៣២៣នាក់ ក្រុមអ្នកស្តាប់ព្រះបន្ទូលចំនួន១៩៩នាក់ និងក្រុមពន្លកថ្មីចំនួន២០៩នាក់។ វណ្ណា



Photo: Davith

ដល់កំរិតឧត្តមសិក្សាផងដែរ។ ចំពោះសាសនាឥស្លាម ការអប់រំសាសនានៅតាមសហគមន៍រីតតែខ្វះមធ្យោយទៅទៀត។ “យើងជួបការលំបាកច្រើន។ គ្រូបង្រៀនទទួលប្រាក់ខែពីការរៃអង្គាសពីឪពុកម្តាយសិស្សតាមរយៈព្រះវិហារ”។ នេះជាការបញ្ជាក់របស់លោក សុះ កាំុ។

**តើយុវជនត្រូវការជំនួយពីសាសនា?**

បច្ចុប្បន្ន សាសនាពុំទាន់មានជំហរទីតាំងពិតប្រាកដសំរាប់ឆ្លើយតបនូវតំរូវការយុវជនទេ។ លោក អ៊ុំង ចំរើន បានចាប់អារម្មណ៍ចំពោះសាសនាដែលដឹកនាំចិត្តឱ្យប្រកាន់ភ្ជាប់នូវសីលធម៏ខ្ពស់ ក្នុងការប្រាស្រ័យទាក់ទងគ្នា។ ប៉ុន្តែ ទស្សនៈអោយតំលៃមនុស្សដូចគ្នាគឺមានភាពសំខាន់ជាជាងការគោរពប្រតិបត្តិសាសនាទៅទៀត។ លោកបានរៀបរាប់ថា: “អ្វីដែលល្អនោះ គឺមិនចាំបាច់ទាល់តែទៅវត្តទេ ប៉ុន្តែត្រូវមានទស្សនៈឱ្យតំលៃមនុស្សដូចគ្នា។ ចំពោះលោក នឹម តៅ និស្សិតឆ្នាំទីពីរផ្នែកទស្សនវិជ្ជា នៅទេវវិទ្យាល័យតែងមានជំនឿលើភារកិច្ចជាបូជាចារ្យរបស់គាត់នាពេលអនាគត។ លោកកត់សំគាល់ថា: “វាជាបទពិសោធន៏ខុសពីមនុស្សសាមញ្ញ ហើយអាចជួយគេបានច្រើនតាមរយៈការគោរពគ្នាទៅវិញទៅមក”។

បូលីន ដាវីដ

# សាសនាកាន់តែរីកចំរើន

**ប្រទេសកម្ពុជាបានបើកទ្វារចំហសំរាប់ឱ្យប្រជាជនប្រកាន់នូវជំនឿសាសនាផ្សេងៗ។ ក្នុងនោះដែរ សាសនាគ្រិស្ត ព្រះពុទ្ធ និងឥស្លាមសាសនាកំពុងកសាងនូវមូលដ្ឋានគ្រឹះរៀងៗខ្លួន។**

សព្វថ្ងៃនេះ គេអាចសង្កេតឃើញការរីកចំរើនលើវិស័យសាសនានៅប្រទេសកម្ពុជាតាមផ្លូវពីរគឺ ផ្លូវសំភារៈ និងផ្លូវជំនឿ។ សាសនាធំៗទាំងបីបានជ្រៀតចូលនៅទូទាំងប្រទេស។

ខាងក្រោមនេះគឺជាស្ថិតិខ្លះនៃសមិទ្ធិផល និងមូលដ្ឋានគ្រឹះអប់រំនៃសាសនានីមួយៗ។

**ព្រះសហគមន៏កាតូលិក**

ត្រូវបានចែកចេញជា៣ភូមិភាគ:

ភូមិភាគភ្នំពេញ មាន២០ព្រះសហគមន៏ មានបូជាចារ្យបំរើ១០នាក់ រួមនឹងលោកបូជាចារ្យបងប្រុស បងស្រី តាមអង្គការផ្សេងៗទៀត។

ភូមិភាគកំពង់ចាម គឺមាន១៧ព្រះសហគមន៏ មានលោកបូជាចារ្យបំរើការងារ ចំនួន៩នាក់ ព្រមទាំងបងប្រុស បងស្រីមួយចំនួនទៀត។

ភូមិភាគបាត់ដំបង គឺមាន២៤ព្រះសហគមន៏ លោកបូជាចារ្យបំរើការងារចំនួន១២នាក់ រួមនឹងបងប្រុសបងស្រីមួយចំនួនទៀត។

**ព្រះពុទ្ធសាសនា**

គណៈមហានិកាយមាន៣.៩៣៨វត្ត និងព្រះសង្ឃមានចំនួន៥៨.៤៧៩អង្គ។ ចំណែកគណៈធម្មយុត្តិមាន១២២វត្ត។ ព្រះសង្ឃមានចំនួន១.២៥៩អង្គ។ សរុបទាំងពីរគណៈ មានវត្តចំនួន៤.០៦០ និងព្រះសង្ឃចំនួន ៥៩.៧៣៨អង្គ។ នៅក្នុងវិស័យពុទ្ធិកសិក្សា មានសាលាពុទ្ធិកសិក្សាបឋមចំនួន៥៧២សាលា មានសមណសិស្សចំនួន១៥.៦៣៧អង្គ។ ដោយឡែកពុទ្ធិកវិទ្យាល័យមាន១៩សាលា គឺនៅភ្នំពេញ៧សាលា និងតាមបណ្តាខេត្តមាន១២សាលា។ សព្វថ្ងៃនេះ សមណសិស្សដែលតែកំពុងសិក្សាមានចំនួន ៣.៩៣៣អង្គ។

ចំពោះកំរិតឧត្តមសិក្សាវិញ ពុទ្ធិកមហាវិទ្យាល័យ មាន១កន្លែងនៅភ្នំពេញ គឺពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ ដែលមានសមណនិស្សិត២៦៥អង្គ។ ការសិក្សាថ្នាក់បរិញ្ញាប័ត្រត្រូវបានចែកចេញជាពីរផ្នែក គឺវិទ្យាសាស្រ្តអប់រំ និងទស្សនវិជ្ជាព្រះពុទ្ធសាសនា។ គ្រូក្របខ័ណ្ឌពុទ្ធិកបឋមសិក្សាមាន៩០រូប ហើយនិងសាស្រ្តាចារ្យពុទ្ធិកមធ្យមសិក្សាបឋមភូមិមានចំនួន ២៦រូប។ ស្របគ្នាផងដែរ សាលាធម្មវិន័យ ដែលជាមូលដ្ឋានគ្រឹះសំរាប់សមណសិស្សបន្តវិជ្ជាទៅពុទ្ធិកបឋមសិក្សា គ្រប់គ្រងដោយវត្តផ្ទាល់មានសាលាចំនួន៧៦៨ និងសមណសិស្សចំនួន ១៥.៨៣៦អង្គ។

**សាសនាឥស្លាម**

ប្រជាជនខ្មែរឥស្លាមមានចំនួនប្រហែល ៥០០ ០០០នាក់ ដែលចេញមកពីភូមិចំនួន៤៨នៅក្នុងប្រទេសកម្ពុជា។ ស្របគ្នានោះដែរ ព្រះវិហារ និងសូរាវ (កន្លែងសូត្រធម៏តាមភូមិ) មានចំនួន៤៨។ ចំពោះ អ៊ីម៉ាម អ្នកដឹកនាំភូមិក៏មានចំនួនដូចគ្នា នឹងវត្តមានព្រះវិហារ ដែលមាននៅទូទាំងប្រទេសផងដែរ។

សមាគមឥស្លាមដែលទទួលការគាំទ្រពីបណ្តាប្រទេសកាន់សាសនាឥស្លាមមានចំនួន២០។

បូលីន ដាវីដ



ការបង្រៀនព្រះគម្ពីរកូរ៉ាន់នៅក្នុងសាសនាឥស្លាម

Photo: P.R

# ជំនួបនិស្សិតទេវវិទ្យាល័យ

និស្សិតទេវវិទ្យាល័យនៅកម្ពុជាបានធ្វើការជួបជុំគ្នាមួយនៅថ្ងៃទី៨ មករា ២០០៥ នៅឯសណ្ឋាគារ Paradie ក្រោមអធិបតីភាពលោកប៊្រុយណូ និងលោកម៉ារីយ៉ូ ដែលអ្នកទទួលខុសត្រូវទេវវិទ្យាល័យភ្នំពេញ។ និស្សិតទាំងនោះមកពីប្រទេសបារាំង កូឡុំប៊ី អេក្វាដ័រ អាមេរិក សាំងហ្គាពួ និងកម្ពុជា។ គោលដៅសំខាន់របស់ជំនួបនេះគឺដើម្បីចែករំលែកបទពិសោធន៍អំពីការរស់នៅ គំរោងការ ការទទួលខុសត្រូវ ការត្រាស់ហៅ និងការចែកបទពិសោធន៍នៃជំនឿ និងក្ដីស្រមៃពីអនាគតជាបូជាចារ្យ និងជាសាសនទូតបំរើការក្នុងប្រទេសក្រីក្រ ដូចជាប្រទេសកម្ពុជាជាដើម។ នេះគឺជាឱកាសមួយសំរាប់ជួយលើកទឹកចិត្តដល់និស្សិតទេវវិទ្យាល័យកម្ពុជាឱ្យបន្តការខិតខំជួយកសាងព្រះសហគមន៍និងដើម្បីឱ្យស្គាល់គ្នាទៅវិញទៅមក។ ព្រះសហគមន៍នៅកម្ពុជាមានសេចក្ដីសង្ឃឹមថា នៅពេលអនាគត នឹងមានបូជាចារ្យថ្មីៗដែលចេញពីព្រះសហគមន៍ខ្មែរ។ ការជួបជុំគ្នាជាលើកដំបូងរវាងនិស្សិតទេវវិទ្យាល័យនៅកម្ពុជានេះគឺការល្អប្រសើរខ្លាំងណាស់។ ហើយយើងតាំងចិត្តនឹងធ្វើតាមការរៀបចំរបស់នាយកទេវវិទ្យាល័យភ្នំពេញ។អេរ៉ាន់



Photo: DR

ការលេងល្បែងកំសាន្ត ជាមួយក្មេងអនាថា

# មរណភាពមាតាលោក ឆ្មារ សាឡាស

លោកយាយ ម៉ាការីតា ថោងត្រឃួន ជាមាតាលោកអភិបាល ឆ្មារ សាឡាស (១៩៤០-១៩៧៧) បានទទួលមរណភាពនៅថ្ងៃទី២២ មករា ឆ្នាំ២០០៥ ក្នុងជន្មាយុ៩២ឆ្នាំដោយរោគាព្យាធិ។ ព្រះសហគមន៍ និងគ្រិស្តបរិស័ទទាំងអស់បានសម្ដែងនូវសេចក្ដីក្រៀមក្រំ និងចូលរួមរំលែកទុក្ខដល់ក្រុមគ្រួសារសពលោកយាយ។ យើងទាំងអស់គ្នាសូមអរព្រះគុណដល់ព្រះជាម្ចាស់ដែលប្រោសប្រទានលោកយាយ ឱ្យមានជំនឿយ៉ាងរឹងមាំ និងហ៊ានលះបង់គ្រប់បែបយ៉ាងដើម្បីបំរើព្រះសហគមន៍របស់ព្រះអង្គ។ លោកយាយសុខចិត្តរស់នៅក្នុងជីវភាពលំបាកក្នុងគោលបំណងឱ្យលោកអភិបាល ឆ្មារ សាឡាស បានទទួលអគ្គសញ្ញាតែងតាំងជាបូជាចារ្យនៅឆ្នាំ១៩៦៤ និងជាអភិបាលព្រះសហគមន៍ថ្ងៃទី១៤ មេសា ឆ្នាំ១៩៧៥ នៅគ្រាដែលប្រទេសកម្ពុជាគ្មានបូជាចារ្យជាជនជាតិខ្មែរ។ នេះគឺជាសក្ខីភាពមួយរំលឹកដល់យើងជា [illegible]

សំ រ៉ានី

# ទុគ៌តជននៅកំពង់ចាម

នៅថ្ងៃបុណ្យចូលឆ្នាំសកល២០០៥ ព្រះសហគមន៍កំពង់-ចាមមានប្រារព្ធពិធីជប់លៀងមួយសំរាប់ទុគ៌តជន អ្នកក្រីក្រ និងក្មេងអនាថាប្រមាណជា១៣២នាក់ក្រោមបរិយា-កាសយ៉ាងសប្បាយរីករាយ។ តាមប្រសាសន៍របស់បងស្រីស៊ីសំផន ដែលជាប្រធានផ្នែកអប់រំអនាម័យបានឱ្យដឹងថា: "រយៈពេលពីរថ្ងៃមុនប្រារព្ធពិធីនេះយុវជននៃព្រះសហគមន៍កំពង់ចាមបានចុះចែកលិខិតអញ្ជើញដល់ពួកគេ"។ នៅក្នុងពិធីនោះមានការលេងល្បែងកំសាន្ត ការច្រៀងរាំ ការបញ្ចាំងខ្សែភាពយន្ត ព្រមទាំងមានការសម្ដែងរបាំពីក្រុមយុវជនកោះរកាផងដែរ។ បងស្រីបានបន្ថែមទៀតថា: "ខ្ញុំមានចិត្តរំភើបណាស់ ពីព្រោះព្រះសហគមន៍បានផ្ដល់ភាពកក់ក្ដៅដល់ទុគ៌តជន ក៏ដូចជាក្មេងអនាថាទាំងនោះដោយមិនឱ្យពួកគេនៅឯកោតែម្នាក់ឯង"។ នៅពេលចុងបញ្ចប់នៃកម្មវិធីក៏មានការចែកជូននូវកាដូជាក្រមាមុនពេលពួកគេត្រលប់ទៅកន្លែងដើមវិញ។

រ៉ូ បូរ៉ា

# សុខភាព

## រដូវប្រចាំខែរបស់ស្ត្រីជាអ្វី?



Photo: Theary

បងស្រី Virginia Irang នៃក្រុមគ្រួសារមេត្តាករុណា មានតួនាទីជាអ្នកបញ្ជូន និងថែរក្សាអ្នកជំងឺនៅឯព្រះវិហារផ្សារតូច

មនុស្សស្រីផ្ដើមមានរដូវនៅអាយុ ១៣ឆ្នាំ ហើយបាត់វិញនៅអាយុ៤៥ ឬ៥០ឆ្នាំ។ ការមករដូវមាន២ដំណាក់កាល ដំណាក់កាលទី១ គឺការធ្លាក់ស និងទី២ គឺការមករដូវ ព្រោះអូវុលនៅក្នុងខ្លួនស្ត្រីក្រមុំមិនបានជួបជាមួយស្ពែម៉ាតូស្សូអ៊ីតរបស់បុរស ដូច្នេះឈាមដែលបំរុងចិញ្ចឹមគត៌នៅក្នុងស្បូន ក៏ធ្លាក់ចេញមកក្រៅ។ វាតែងកើតមានជារៀងរាល់ខែ។ មុនពេលមករដូវ ស្ត្រីមានអាការៈ ឈឺ ក្បាល អស់កំលាំង ឈឺដើមទ្រូង ឈឺចង្កេះ តែវាមិនមានបញ្ហាធំដុំទេ។ ការមករដូវនេះ គឺមានរយៈពេលពី៧-៨ថ្ងៃ។ ដើម្បីបង្ការការឈឺចាប់នោះ យើងមិនត្រូវធ្វើការងារធ្ងន់ មិនត្រូវញ៉ាំអាហារដែលមានជាតិហិរ ជូរ និងសុរាឡើយ។ យើងអាចហាត់ប្រាណពី៥-១០នាទី ដោយចលនាយឺតៗដើម្បីបន្ថយការឈឺចាប់ និងសំរាកឱ្យបានច្រើន។ ប៉ុន្តែប្រសិនបើយើងនៅតែឈឺខ្លាំងទ្រាំមិនបាន យើងអាចលេបថ្នាំគីណាល់ ឬថ្នាំប៉ារ៉ាសេតាម៉ុល តែក៏មិនអាចប្រើវាជារៀងរាល់ថ្ងៃបានដែរ ហើយត្រូវចងចាំថាមិនត្រូវប្រើថ្នាំអាស្ពីរីនឡើយ។ ម្យ៉ាងទៀតយើងក៏អាចផឹកទឹកដូងដើម្បីបំបាត់ការឈឺចាប់ ហើយនេះក៏នឹងអាចបន្ថយការឈឺចាប់នៅពេលមករដូវលើកក្រោយទៀតបានដែរ។

មុំ គន្ធា និងហ៊ួ សុខធារី

# ថ្ងៃនៃក្តីស្រលាញ់ Valentine's Day

**នៅថ្ងៃទី១៤កុម្ភៈជារៀងរាល់ឆ្នាំ នៅតាមទីប្រជុំជននានា ស្ករគ្រាប់ ផ្កា និងរង្វាន់ជាច្រើនទៀតត្រូវបានជូនឱ្យដល់គ្នាទៅវិញទៅមករវាងអ្នកស្រឡាញ់។ តើអ្វីទៅជា Valentine's Day ?**



Photo: L. Sovanna

ការប្រគល់ផ្កាកូលាបក្រហមដែលតំណាងឱ្យសេចក្តីស្រលាញ់នៅថ្ងៃបុណ្យសង្សារ

Valentine ជាឈ្មោះរបស់សន្តជនជាតិអ៊ីតាលីមួយរូបដែលជាបុព្វបុរសដ៏អស្ចារ្យនៅក្នុងសាសនាគ្រិស្ត ហើយក៏ជាសន្តមួយរូបដែលល្បី នៅប្រទេសអង់គ្លេស និងប្រទេសបារាំង។ តាមពិត គេនាំគ្នាធ្វើពិធីបុណ្យនេះឡើងគឺដើម្បីធ្វើការរំលឹកដល់ថ្ងៃទទួលមរណភាពរបស់លោក Valentine ដែលត្រូវបានគេសម្លាប់ក្នុងអំឡុងឆ្នាំ២៧០គ្រិស្តសករាជ។ នៅខណៈពេលដែលគាត់ជាប់នៅក្នុងមន្ទីរឃុំឃាំង គាត់បានធ្លាក់ចូលទៅក្នុងអន្លង់ស្នេហ៍របស់ក្មេងស្រីម្នាក់ដែលជាកូនរបស់ឆ្មាំគុកនៅពេលដែលនាងមកសួរសុខទុក្ខគាត់។ នៅមុនពេលដែលគាត់ស្លាប់ គាត់បានសរសេរសំបុត្រមួយច្បាប់ទៅឱ្យនាងដោយសរសេរថា "ពី Valentineរបស់អ្នក" ដែលពាក្យនេះនៅមានប្រើរហូតមកដល់សព្វថ្ងៃ។

ក្នុងថ្ងៃនោះផងដែរ សំរាប់ប្រទេសកម្ពុជា ជាពិសេសនៅរាជធានីភ្នំពេញ យើងសង្កេតឃើញនៅពីមុខហាងលក់ផ្កា ក៏ដូចជាតូបលក់ផ្កាទាំងឡាយនៅក្នុងទីក្រុងភ្នំពេញមានមនុស្សច្រើនកុះករចូលទិញផ្កាដែលក្នុងនោះភាគច្រើនជាយុវជន។ អាជីវករលក់ផ្កានៅផ្សារថ្មីម្នាក់បានអោយដឹងថា នៅថ្ងៃនោះគាត់លក់ផ្កាបានចំនួនពី៦០០-១០០០ដើម ដែលសុទ្ធសឹងជាផ្កាកូលាបពណ៌ក្រហម ដែលតាមពេលធម្មតាគាត់លក់បានពី៣០០-៤០០ដើមប៉ុណ្ណោះ។ គាត់បន្តឱ្យដឹងទៀតថា: "ថ្ងៃធម្មតាផ្កាកូលាបមួយដើម គាត់លក់ក្នុងតំលៃ១៥០០រៀលប៉ុណ្ណោះ ក៏ប៉ុន្តែនៅថ្ងៃបុណ្យសង្សារ គាត់លក់ក្នុងតំលៃ១ដុល្លារ " ដែលតំលៃនេះលក់បានតែក្នុងចំនួនពីរថ្ងៃប៉ុណ្ណោះ។ គាត់បានបន្ថែមទៀតថា ថ្ងៃនោះមិនមែនជាថ្ងៃដែលគាត់ធ្វើអាជីវកម្មផ្កាទេគឺគ្រាន់តែជាថ្ងៃមួយដែលយុវវ័យភាគច្រើនចាប់អារម្មណ៍ទៅលើផ្ការបស់គាត់។

កញ្ញា ស៊ុត ស្វយ៉ុត ជាអតីតនិស្សិតនៅសាកលវិទ្យាល័យជាតិគ្រប់គ្រងបានបង្ហាញអំពីអារម្មណ៍របស់នាងថា: "នាងមានការរំភើប និងមានមោទនភាពចំពោះខ្លួនឯងយ៉ាងខ្លាំងនៅពេលដែលនាងបានទទួលនូវផ្កាមួយបាច់ ពីដៃបុរសដែលស្រឡាញ់រូបនាង។ នាងបាននិយាយដោយទឹកមុខញញឹមថា ពីមុននាងពុំដែលឃើញមាននរណាធ្វើបុណ្យនេះឡើងទេ តែឥឡូវនេះ នៅពេលដល់ថ្ងៃនេះមានអ្នកជូនផ្កា ជូនកាដូ ឬជាបណ្ណផ្សេងៗ ឱ្យគ្នាទៅវិញទៅមក។

បុណ្យនេះមានលក្ខណៈល្អដើម្បីបង្ហាញអំពីទឹកចិត្តនៃសេចក្តីស្រឡាញ់របស់ខ្លួនទៅកាន់អ្នកដែលយើងស្រឡាញ់។ នៅថ្ងៃខាងមុខបុណ្យនេះប្រហែលជាអាចក្លាយជាបុណ្យប្រពៃ-ណីខ្មែរមួយ ប៉ុន្តែវាមិនដល់ថ្នាក់ថាជាលក្ខណៈបុណ្យជាតិទេ គ្រាន់តែវាមានអ្នកទទួលស្គាល់ច្រើនជាងសព្វថ្ងៃនេះ។

ក្នុងនោះដែរលោក វាសនា ជាបុរសម្នាក់ដែលមានការពេញចិត្តបំផុតទៅនឹងថ្ងៃបុណ្យសង្សារនេះ និយាយអះអាងថា: "ខ្ញុំយល់ថាថ្ងៃ១៤កុម្ភៈនេះ គឺជាថ្ងៃដ៏ពិសេសសំរាប់រូបខ្ញុំក្នុងការបង្ហាញពីសេចក្តីស្រឡាញ់របស់ខ្ញុំចំពោះនារី ដែលខ្ញុំបានស្រឡាញ់។ ម្យ៉ាងទៀត វាក៏មិនមែនតែរូបខ្ញុំនោះទេ គឺស្ទើរតែគ្រប់បុរសទាំងអស់នៅទូទាំងប្រទេស "។

ស្របពេលជាមួយនេះ ក៏មានទស្សនៈមួយចំនួនធ្វើការរិះគន់ទៅលើបុណ្យនេះផងដែរថា ក្មេងៗសម័យនេះហាក់បីដូចជាភ្លើតភ្លើនជ្រុល ដោយមានការទទួលយកនូវវប្បធម៌ពីបរ-ទេសច្រើន មានដូចជាបុណ្យសង្សារនេះជាដើម។

មុំ គន្ធា

## អត្ថន័យពណ៌ផ្កាកូលាប:

ពណ៌ក្រហម: ស្រឡាញ់ គោរព ស្រឡាញ់អ្នក!។

ពណ៌ផ្កាឈូក: មានសុភមង្គលល្អ សុភាពរម្យទម និងការផ្តល់កិត្តិយស។

ពណ៌លឿង: មិត្តភាពរីករាយ និងសុភមង្គល។

ពណ៌ស: ចិត្តបរិសុទ្ធ ភាពអាថ៌កំបាំង ព្រមទាំងភាពស្ងាត់ស្ងៀម

ពណ៌ទឹកក្រូច: សេចក្តីសាទរ សេចក្តីប្រាថ្នា

មួយទងវែង: ខ្ញុំនឹងចងចាំអ្នកគ្រប់ពេលវេលា។

-មួយទងខ្លី: គូសង្សារវ័យក្រមុំ។

ចំរុះពណ៌: អ្នកគឺជាអ្វីៗគ្រប់យ៉ាងសំរាប់ខ្ញុំ។

# ឆ្នាំរកា ទាមទារនូវការព្យាយាម

**ជនជាតិចិន-វៀតណាមតែងប្រារព្ធធ្វើបុណ្យចូលឆ្នាំនៅចន្លោះចុងខែមករា និងដើមខែកុម្ភៈ។ ឆ្នាំថ្មីគឺចង់បញ្ជាក់ប្រាប់ពីការផ្តើមឆ្នាំច័ន្ទគតិនិងការឈានចូលមកដល់នៃរដូវផ្ការីក។ ជារៀងរាល់ឆ្នាំថ្មីតែងមាននិមិត្តសញ្ញាសត្វសំគាល់ជានិច្ច។**

---

បុណ្យចូលឆ្នាំចិន-វៀតណាម ជាប្រពៃណីដ៏មានប្រជាប្រិយបំផុតមួយសំរាប់ជនជាតិចិន និងវៀត-ណាម។ នៅបណ្តាប្រទេសទាំងឡាយ ដែលមានប្រជាជនចិនរស់នៅច្រើន ពិធីបុណ្យនេះមានការរៀបចំអធិកអធមណាស់។ ឆ្នាំចាស់ជាឆ្នាំវក ជាឆ្នាំដែលបង្ហាញឱ្យឃើញនូវការជជែកពិភាក្សា និងផ្លាស់ប្តូរនូវគំនិតថ្មី។ នៅឆ្នាំ២០០៥ នេះនិមិត្តសញ្ញាហោរាសាស្រ្តតំណាងឱ្យឆ្នាំរកាគឺមានរូបសត្វមាន់ជាសំគាល់។ លោក ង្វៀង ថាន់លីម អាយុ៩១ឆ្នាំ បាននិយាយថាៈ "ចូលឆ្នាំចិន-វៀតណាមមានអត្ថន័យសំខាន់ណាស់សំរាប់បងប្អូនដែលរកស៊ីស្រុកឆ្ងាយៗ ឬ មានភាពមមាញឹក។ នេះគឺជាឱកាសល្អមួយដែលពួកគេអាចជួបជុំគ្នាជូនពរ និងសួរសុខទុក្ខគ្រួសារជិតខាង"។ សំរាប់ឆ្នាំថ្មីនេះ អតីតជាងឈើរូបនេះមិនធ្វើដំណើរទៅប្រទេសវៀតណាមទេ ពីព្រោះ គាត់បានទៅសួរសុខទុក្ខគ្រួសារកាលពីឆ្នាំមុនរួចហើយ។ ម៉្យាងទៀតនៅក្នុងព្រះសហគមន៍ ទួលតាំង ក្បែរសង្កាត់ច្បារអំពៅនោះ លោកត្រូវជាប់រវល់រៀបចំពិធីបុណ្យចូលឆ្នាំ ព្រោះលោកជាសមាជិកគណៈកម្មការព្រះវិហារ។ ព្រះសហគមន៍ទួលតាំងនេះមានគ្រិស្តបរិស័ទវៀតណាមប្រមាណ១០០គ្រួសារ។



Photo: L. Davith

**ម៉ុងសាយត្រូវបានសម្តែងនារដូវចូលឆ្នាំតាមប្រពៃណីចិនដើម្បីកំចាត់ឧបទ្រពចង្រៃ**

សំរាប់ជនជាតិវៀតណាមដែលរស់នៅ និងប្រកបការងារនៅកម្ពុជា បុណ្យចូលឆ្នាំចិន-វៀតណាមគឺជាឱកាសដែលពួកគេអាចធ្វើដំណើរ បានងាយស្រួល ព្រោះខេត្តនានាដែលនៅតាមព្រំដែនរវាងប្រទេសទាំងពីរ តែងមានការបើកទូលាយឱ្យប្រជាជនទាំងពីរប្រទេសចេញចូលដោយសេរី។

**នំអន្សមជ្រូកជាប្រពៃណីក្នុងបុណ្យចូលឆ្នាំ**

តាមប្រពៃណីបានឱ្យដឹងថាការផុតឆ្នាំចាស់ផ្លាស់ចូលឆ្នាំថ្មីនេះជាការផ្តើមចូលឆ្នាំច័ន្ទគតិ។ ចំពោះជនជាតិវៀតណាម នំអន្សមជ្រូកមានតួនាទីសំខាន់ណាស់ក្នុងពិធីនេះ សំរាប់សែនថ្វាយទេវតា និងដូនតាដែលបានទទួលមរណកាលទៅ។ អន្សមជ្រូក នេះ គេហៅតាមភាសាវៀតណាមថា "បាន់តែក" ដែលធ្វើឡើងអំពីអង្ករដំណើបដាក់លាយដោយស្ពូលសាច់ជ្រូក និងសណ្តែកសៀង។ "ការធ្វើនំអន្សមនេះគឺធ្វើតាមប្រពៃណីបុរាណកាលដែលកសិករយកអង្ករដំណើបដែលបានមកពីការប្រមូលផលស្រូវ មកកែច្នៃធ្វើជានំ" នេះជាការពន្យល់របស់លោកថាន់ លីម។ ក្រៅពីនោះ ការសែនព្រេនផ្លែឈើ និងបន្ថែបង្អាផ្សេងៗ គឺចង់បង្ហាញពីការដឹងគុណរបស់កូនចៅចំពោះដូនតា។

**"យើងមិនអាចធ្វើដូចបុរាណបានទេពីព្រោះជីវភាពគ្រួសារក្រ"**

ការរៀបចំផ្ទះសំបែងសំរាប់ស្វាគមន៍ឆ្នាំថ្មីមានសារៈសំខាន់ណាស់។ គេតុបតែងផ្ទះទៅដោយក្រដាសពណ៌ទឹកមាស និងពណ៌ក្រហមជាមួយនឹងភ្លើងអំពូលចំរុះពណ៌។ លើសពីនេះកិច្ចការផ្ទះត្រូវបានហាមប្រាមមិនអោយធ្វើ។ រីឯអំបោសត្រូវយកទៅលាក់ទុកមួយកន្លែងខ្លាចក្រែងលោភ័ព្វសំណាងរសាត់តាមការបោសសំអាតផ្ទះ។ ផ្ទុយទៅវិញ សំរាប់គ្រួសារអ្នកស្រី ហេង ស្រីពុំមានលទ្ធភាពរៀបចំពិធីបុណ្យចូលឆ្នាំឱ្យដូចតាមប្រពៃណីឡើយ។ មុខរបរធ្វើក្រចករបស់គាត់ពុំបានផ្តល់ជីវភាពធូរធារឱ្យគាត់ឡើយ។ គាត់បាននិយាយថាៈ "ឥឡូវនេះ យើងមិនអាចធ្វើឱ្យដូច




## ការទស្សន៍ទាយជោគវាសនានៅឆ្នាំថ្មី ឆ្នាំរកា

ឆ្នាំរកាដែលមាននិមិត្តសញ្ញាសត្វមាន់ជាសំគាល់។ សត្វនេះត្រូវបានគេសំគាល់ថាមានចរិកលក្ខណៈក្រអឺតក្រទមហើយតែងលើកតម្កើងខ្លួនខ្ពស់កប់ពពក។ ឆ្នាំថ្មីនេះពោរពេញទៅដោយសន្ទុះចិត្តពុះកញ្ជ្រោល និងនាំមកនូវគំនិតថ្មៃប្រឌិតថ្មីៗប្រកបដោយមហិច្ឆិតា។ ប៉ុន្តែ ទោះជាយ៉ាងណាក៏ដោយ អ្នកដែលកើតឆ្នាំនេះកុំអាលត្រេកអរពេក គឺត្រូវបង្កើនការជឿជាក់លើខ្លួនឯង។ ម៉្យាងទៀត ត្រូវតែប្រយ័ត្នប្រយែងកុំបន្ទលង់លក់ក្នុងការស្រមើស្រមៃហើយត្រូវឆ្លៀតក្រលេកមើលអ្វីដែលមាននៅក្រោមជើងខ្លួនផង បើពុំនោះទេប្រាកដជាភ្លាត់ស្នៀតដួលបោកក្បាលជាក់ជាមិនខាន។ គួរចងចាំថា បើចង់ជោគជ័យក្នុងការងារគ្រប់វិស័យទាំងអស់ក្នុងឆ្នាំថ្មីនេះ មិនត្រូវផ្តេកផ្តួលលើភ័ព្វសំណាង វីសភាវគតិទេ។ ប៉ុន្តែ ត្រូវទុកចិត្តលើការងារ និងសេចក្តីព្យាយាម។ និយាយឱ្យខ្លីឆ្នាំរកាគឺជាឆ្នាំត្រូវការឱ្យមានគំនិតចាស់ទុំ។

សម័យបុរាណបានទេដោយសារជីវភាពគ្រួសារក្រីក្រ។ យើងត្រូវធ្វើការងារ រកប្រាក់មករៀបចំពិធីសែន និងចិញ្ចឹមគ្រួសារ”។ ជារៀងរាល់ឆ្នាំគ្រួសារនីមួយៗ ចំណាយលុយជាមធ្យមលើការទិញទំនិញសំរាប់ពិធីសែនអស់ ចន្លោះពី១០ទៅ២០ម៉ឺនរៀល។ ទាំងនេះមិនទាន់គិតដល់ការទិញសំលៀកបំពាក់ថ្មីៗ និងធ្វើអំណោយជាទឹកប្រាក់ក្រដាសថ្មីស្រឡាងដល់សមាជិកក្នុងគ្រួសារដែលត្រូវចំណាយប្រាក់ប្រមាណជិត១០០ដុល្លារ។ ឆ្នាំរកាជាឆ្នាំដែលហោរាសាស្ត្រយល់ថា ត្រូវទាមទារឱ្យមានការឧស្សាហ៍ព្យាយាម។ គេត្រូវប្រើប្រាស់ប្រាជ្ញាស្មារតីខិតខំធ្វើការងារ។

បូលីន ដាវីដ និងភី ឡុង



Photo: P. Samphy

ផ្លែ និងជ្រូកខ្វៃដែលត្រូវដាក់សែនដើម្បីថ្វាយដល់ទេវតានិងជីដូនជីតាដែលបានចែកឋានទៅលោកខាងមុខ

# ជំនឿនៅពេលបុណ្យចូលឆ្នាំ

**នេះជាកំណត់សំគាល់ខ្លះៗដែលបានចាក់ឫសក្នុងផ្នត់គំនិតគ្រួសារជនជាតិចិននិងវៀតណាម។ នៅកម្ពុជា កូនចៅខ្មែរកាត់ចិនក៏តែងប្រកាន់ជំនឿនេះដែរ។**

---

### ១-ការរៀបចំផ្ទះសម្បែង

**ផ្លែក្រូចខ្វិច** គឺជាផ្លែឈើដែលតំណាងដល់សុខភាពដ៏ល្អបរិបូណ៌។

**ផ្កាអង្គារសីល្បិ៍** ជានិមិត្តរូបនៃភាពចំរុងចំរើន។ ចំពោះដើមណាដែលចេញផ្កាចំថ្ងៃចូលឆ្នាំតែម្តងនោះ សបញ្ជាក់ឱ្យឃើញអំពីភាពសម្បូរសប្បាយក្នុងឆ្នាំថ្មី។ ចំពោះផ្កាដែលរីកយ៉ាងល្អនោះប្រាប់ឱ្យឃើញពីភាពសម្បូរទ្រព្យសម្បត្តិ និងការជោគ-ជ័យសំរាប់ជីវិតរស់នៅក្នុងសង្គម។

**ផ្កាស្បៃរឿង** សំគាល់មិត្តភាពស្និទ្ធស្នាលរវាងគ្នានិងគ្នានៅក្នុងគ្រួសារ និងរវាងមិត្តភក្តិ។

**ដើមឫស្សី** តំណាងឱ្យទំនុកចិត្ត ភាពឧស្សាហ៍ព្យាយាម និងភាពទន់ភ្លន់។

### ២-ការទៅផ្សារ និងរៀបចំម្ហូបអាហារ

គេត្រូវទៅផ្សារទិញឥវ៉ាន់ឱ្យបានសព្វគ្រប់មិនឱ្យខ្វះមុខខ្វះក្រោយសំរាប់ការសែនព្រេនក្នុងថ្ងៃចូលឆ្នាំ និងសំរាប់ធ្វើជាកាដូជូនមិត្តភក្តិ និងបងប្អូន។ មួយថ្ងៃមុនចូលឆ្នាំ គេត្រូវរៀបចំធ្វើម្ហូបអាហារឱ្យបានស្រេចបាច់ដើម្បីទុកបរិភោគ ក្នុងថ្ងៃសែន ពីព្រោះតាមប្រពៃណីគេហាមមិនឱ្យប្រើប្រាស់ឧបករណ៍ផ្ទះបាយឡើយ ដោយខ្លាចក្រែងកាត់ផ្តាច់សំណាង។ ពេលថ្ងៃចូលឆ្នាំថ្មីមកដល់ គេរៀបចំម្ហូបអាហារជាច្រើនសំរាប់ទទួលទានដើម្បីនាំមកនូវសុភមង្គលភ័ព្វសំណាងជោគជ័យ និងអាយុវណ្ណៈ។ ចំពោះត្រី គេត្រូវតែបរិ-ភោគទាំងមូលតាំងពីក្បាលដល់កន្ទុយ ដើម្បីឱ្យទទួលនូវភាពមានបានសម្បូរសម្បត្តិហូរហៀរ។ ហេតុអ្វីបានជាគេរៀបចំបន្លែពណ៌បៃតងសំរាប់សែន? ពីព្រោះគេយល់ថាបន្លែខៀវនេះតំណាងភាពយុវវ័យ និងភាពស្រស់ថ្លាក្នុងផ្លូវគំនិត។

### ៣-ការបោសផ្ទះសម្បែង

គេត្រូវបោសសំអាតផ្ទះឱ្យបានល្អរួចហើយត្រូវទុកអំបោសកុំឱ្យអ្នកណាយកទៅប្រើប្រាស់នៅក្នុងថ្ងៃចូលឆ្នាំ ពីព្រោះគេតែងគិតថាបើសិនជាគេបោសសំអាតផ្ទះក្នុងថ្ងៃចូលឆ្នាំនឹងប្រាកដជាធ្វើឱ្យម្ចាស់ផ្ទះនោះបាត់បង់សំណាងដែលត្រូវហើរចេញជាមួយនឹងធូលី។

### ៤-ការសែនបន់ស្រន់ជូនដូនតា និងការសួរសុខទុក្ខមិត្តភក្តិ

ជាធម្មតា គេតែងឧទ្ទិសគោរពព្រះ និងដូនតានៅថ្ងៃចូលឆ្នាំដោយអញ្ជើញពួកគាត់ឱ្យពិសារអាហារដែលមានដាក់សែននៅលើតុនិងរានទេវតា។ នៅថ្ងៃបន្តបន្ទាប់ គេតែងទៅលេងផ្ទះមិត្តភក្តិ និងបងប្អូនដើម្បីជូនពរគ្នាទៅវិញទៅមក។

# មហារលកយក្ស អង្រួនពិភពលោក

កាលពីដំណាច់ឆ្នាំ២០០៤ ពិភពលោកយើងបានជួបប្រទះនូវមហាព្រឹត្តិការណ៍មួយដែលទាំងអស់គ្នាមិននឹកស្មានដល់។ មហារលកយក្ស ឬTsunami បានវាយប្រហារប្រទេសមួយចំនួននៅជុំវិញមហាសមុទ្រឥណ្ឌា ដែលធ្វើឱ្យមនុស្សស្លាប់រងរបួស និងហេដ្ឋារចនាសម្ព័ន្ធជាច្រើនឥតគណនាត្រូវខូចខាត។ ពេលនេះតាមរយៈអ្នកនាំសារប្រិយមិត្តនឹងបានយល់ថែមទៀតអំពីបាតុភូតនៃគ្រោះធម្មជាតិនេះ។




រូបផ្តុំនៃសំបកផែនដីដែលផ្សំឡើងអំពីសំបកផ្ទាំងទ្វីបជាច្រើន។ សំបកផ្ទាំងទ្វីបសំខាន់ៗ មានដូចជាទ្វីបអាមេរិក អឺរ៉ុប-អាស៊ី អាហ្វ្រិក អូស្ត្រាលី និងផ្ទាំងទ្វីបអង់តាក់ទិច។ ការរំកិលប៉ះគ្នានៃផ្ទាំងទ្វីបបង្កើតបានជាការរញ្ជួយដី។

តាមពិត Tsunami ដែលបានវាយប្រហារអាស៊ីកាលពីថ្ងៃទី ២៥ ធ្នូ ២០០៤ គឺបណ្តាលមកពីការរញ្ជួយដីដ៏ធំបំផុតមួយនៅមហាសមុទ្រឥណ្ឌាត្រង់តំបន់កោះ Sumatra ប្រទេសឥណ្ឌូនេស៊ី។ ការរញ្ជួយដីនេះមានកំលាំងរហូតទៅដល់ ៩ រិចទ័រ។ Tsunami ដែលកើតចេញអំពីការរញ្ជួយដីនេះបានសាយឥទ្ធិពលរបស់ខ្លួន រហូតទៅដល់ឆ្នេរខាងកើតនៃទ្វីបអាហ្វ្រិក ដែលមានរយៈចម្ងាយជាង ៦០០០គម។

**ដូច្នេះតើការរញ្ជួយដីមានប្រភពមកពីណា?**

ដំណើរនៃការរញ្ជួយដីនៅលើពិភពលោកត្រូវបានពន្យល់តាមរយៈទ្រឹស្តីអំពីចលនាផ្ទាំងទ្វីបនានា។ សំបកផែនដីត្រូវបានផ្គុំឡើងដោយផ្ទាំងទ្វីបធំៗជាច្រើន ដែលមានកំរាស់រាប់រយគីឡូម៉ែត។ ផ្ទាំងទ្វីបទាំងនេះធ្វើចលនាទៅមកៗ និងរសាត់អណ្តែតលើរំលាយម៉ាក់ម៉ាដែលមាននៅខាងក្នុងស្នូលផែនដី។ ជួនកាលចលនាទាំងនេះអាចធ្វើឱ្យទ្វីបទាំងនោះប៉ះទង្គិចនឹងគ្នា។ ជាក់ស្តែង ការរញ្ជួយដីទាំងឡាយតែងកើតមានឡើងនៅទីប្រសព្វនៃផ្ទាំងទ្វីបទាំងឡាយនេះ។

**អ៊ីចឹងតើ Tsunami គឺជាអ្វីដែរ?**

Tsunami ជាពាក្យក្នុងភាសាជប៉ុនដែលមានន័យថា "រលកនៅកំពង់"។ យើងអាចហៅថា "មហារលកយក្ស" ក៏បាន។ ប៉ុន្តែ អ្នកវិទ្យាសាស្ត្រប្រើប្រាស់ពាក្យនៃភាសាជប៉ុនតាំងពីឆ្នាំ១៩៦៣ ដោយពាក្យនេះមានន័យប្រាកដត្រឹមត្រូវជាង។ Tsunami មានប្រភពមកពីការរញ្ជួយដី បន្ទុះភ្នំភ្លើង ឬ

## បញ្ហាអន្តរជាតិ

# ជនជាតិអ៊ីរ៉ាក់ជំនះភ័យ និងបោះឆ្នោតដើ

**ប្រជាជនអ៊ីរ៉ាក់រាប់លាននាក់បានទៅបោះឆ្នោតក្នុងពេលមានភេរវកម្ម។ តើមេដឹកនាំជាន់ខ្ពស់នឹងអាចធានាឱ្យមានលទ្ធិប្រជាធិបតេយ្យដល់ប្រជាជនបានដែរឬទេ?**

រំឭកព្រឹត្តិការណ៍

ថ្ងៃទី២០ មិនា ២០០៤ ក្រុងវ៉ាស៊ីនតោន និងក្រុមសម្ព័ន្ធមិត្តទាំងឡាយរបស់ខ្លួនបានបើកធ្វើការវាយលុកដោយយោធាមួយប្រឆាំងទៅនឹងអ៊ីរ៉ាក់ ក្រោយពីមានព្រឹត្តិការណ៍នៃការវាយប្រហារភេរវកម្មនៅថ្ងៃទី១១ កញ្ញា ២០០១។

ថ្ងៃ១ ឧសភា លោក G. Bush បានប្រកាសថា សហរដ្ឋអាមេរិកបានឈ្នះសង្គ្រាមហើយ។

ថ្ងៃ៨ មិនា ២០០៤ អ៊ីរ៉ាក់ត្រូវបានគេផ្តល់នូវរដ្ឋធម្មនុញ្ញបណ្តោះអាសន្នមួយដែលចាត់ទុកអ៊ីស្លាមជាសាសនារបស់រដ្ឋ (ជាច្បាប់ធម្មនុញ្ញដែលមិនយកតាមគំរូប្រទេសដទៃ) ហើយដែលធានាឱ្យមានសេរីភាពជាមូលដ្ឋាន និងស្ថាបនានូវប្រព័ន្ធគ្រប់គ្រងបែបសហព័ន្ធមួយ។

ថ្ងៃ២៨ មិថុនា ២០០៤ អាមេរិកបានផ្ទេរអំណាចទៅឱ្យប្រជាជនអ៊ីរ៉ាក់វិញ។ ប្រជាជនអ៊ីរ៉ាក់ទទួលបានសេចក្តីអំពាវនាវឱ្យទៅធ្វើការបោះឆ្នោតនៅថ្ងៃ៣០ មករា ២០០៥ដើម្បីជ្រើសរើសតំណាងរាស្ត្រ ២៧៥រូប ដែលនឹងតាក់តែងនូវច្បាប់រដ្ឋធម្មនុញ្ញ។ ប្រជាជនអ៊ីរ៉ាក់ដែលកាន់សាសនាឥស្លាមនិកាយស៊ីអ៊ីតនឹងចេញទៅបោះឆ្នោតយ៉ាងច្រើនកុះករ។




បំណាក់ស្រុតនៅក្រោមជំរៅទឹកសមុទ្រដែលបង្កើតបានជាមហារលកយក្សដែលធ្វើចលនាប្រដេញគ្នាជាបន្តបន្ទាប់។ នៅក្នុងវិសាលភាពដ៏ធំធេងនៃមហាសមុទ្ររលកយក្សទាំងនេះធ្វើចលនាក្នុងល្បឿនដ៏លឿន ពោលគឺនៅចន្លោះ ពី៥០០ ទៅ៨០០គមក្នុងមួយម៉ោង។ ប៉ុន្តែ នៅពេលជិតទៅដល់ឆ្នេរដែលជំរៅទឹកមិនសូវជ្រៅល្បឿនរបស់រលកថយចុះ។ មុខរលកដែលរៀបប៉ះនឹងឆ្នេរមានកំពស់កើនឡើងយ៉ាងខ្លាំងដែលបង្កើតបានជាជញ្ជាំងទឹកយ៉ាងខ្ពស់វាយសម្រុកមកលើតំបន់ឆ្នេរ (សូមមើលរូប)។

**តើយើងអាចទាយដឹងមុនអំពី Tsunami ដែរឬទេ?**

យើងមិនអាចបញ្ចៀស Tsunami មិនឱ្យកើតមានឡើងបានឡើយ។ ប៉ុន្តែ ប្រព័ន្ធតាមដានត្រួតពិនិត្យមួយចំនួនគឺអាចព្យាករណ៍អំពីការធ្វើដំណើររបស់មហារលកនេះ។ នៅក្នុងមហាសមុទ្រប៉ាស៊ីភិច ប្រព័ន្ធព្រមានអាសន្នត្រូវបានដាក់ឱ្យដំណើរតាំងពីឆ្នាំ១៩៤៨មកម្ល៉េះ។ ប្រព័ន្ធនេះចាប់ព័ត៌មានអំពីការរញ្ជួយដីដែលកើតឡើងភ្លាមៗ និងចលនារបស់ Tsunami។ ដោយមានជំនួយពីផ្កាយរណប ភេរវ-សញ្ញាអាចត្រូវបានផ្តល់ឱ្យដឹងមុនបានជាច្រើនម៉ោង។

ផាត សំភី



មហារលកយក្សរត់បន្តគ្នាយ៉ាងលឿននៅសមុទ្រទឹកជ្រៅ។ ពេលជិតមកដល់ច្រាំងល្បឿនរលកថយចុះ ប៉ុន្តែកើនកំពស់ខ្ពស់ហើយវាយសម្រុកលើតំបន់ឆ្នេរ។

## សត្វមានញាណអភិវឌ្ឍន៍ខ្ពស់

នេះជាហេតុផលដែលពពួកសត្វជាច្រើនអាចគេចផុតពីសេចក្តីស្លាប់នៅពេលTsunami កើតមានឡើងនៅអាស៊ីខាងត្បូង។ នាយិកាមួយរូបនៃសួនសត្វ Vincennes នាទីក្រុង Paris ពន្យល់ថា: "បើប្រៀបធៀបជាមួយនឹងមនុស្សដែលប្រើប្រាស់ភាសា ព្រមទាំងសញ្ញាកាយវិការ ពពួកសត្វមានការអភិ-វឌ្ឍន៍បានល្អប្រសើរជាជាងខាងឃានវិញ្ញាណ និងឆាប់មានអារម្មណ៍ដឹងអំពីការប្រែប្រួលនៃសំពាធបរិយាកាសដោយសារសរីរាង្គពិសេសរបស់ខ្លួន"។ ដូច្នេះ ពួកវាអាចដឹងជាមុនបាននូវព្រឹត្តិការណ៍ខុសប្លែកពីធម្មតា។

# ម្សៅប្រជាធិបតេយ្យ

## ដំណើរការលទ្ធិប្រជាធិបតេយ្យនៅក្នុងឆ្នាំ២០០៥

ថ្ងៃទី៣០ មករា ២០០៥ ប្រជាជនអ៊ីរ៉ាក់បានទៅបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រចំនួន២៧៥រូបដើម្បីបង្កើតសភាអន្តរកាលមួយ។ សភានេះនឹងបង្កើតនូវរដ្ឋាភិបាលអន្តរកាលមួយ ហើយនឹងតែងនូវច្បាប់រដ្ឋធម្មនុញ្ញថ្មីមួយទៀត។ លុះដល់ថ្ងៃ១៥ តុលា ២០០៥: ប្រជាជនអ៊ីរ៉ាក់នឹងទៅបោះឆ្នោតគាំទ្រ ឬប្រឆាំងនឹងរដ្ឋធម្មនុញ្ញថ្មីនេះ។ ដូច្នេះ ប្រសិនបើប្រជាជនគាំទ្ររដ្ឋធម្មនុញ្ញថ្មីនេះ រដ្ឋាភិបាលនិងរដ្ឋសភាជាស្ថាពរនឹងត្រូវបានជ្រើសតាំងឡើង។

P.R






Ali Sistani មេដឹកនាំនិកាយស៊ីអ៊ីត អាយុ៧៣ឆ្នាំកើតនៅអ៊ីរ៉ង់។ គាត់ផ្តើមសិក្សាអំពីសាសនាតាំងពីអាយុ១០ឆ្នាំ។ បន្ទាប់ពីរបបសាដាមជួយរលំគាត់បានលេចមុខលេចមាត់ក្នុងឆាកនយោបាយនិងសាសនានៅប្រទេសអ៊ីរ៉ាក់។

# បុរាណវិទ្យា

**អាជីពខាងបុរាណវិទ្យាហាក់បីដូចជាមិនត្រូវបានគេនឹកនាដល់។ ប៉ុន្តែ អ្នកបុរាណវិទ្យាមានតួនាទីដ៏សំខាន់ គឺគាស់រំលើងតាមរយៈការធ្វើកំណាយនូវអាថ៌កំបាំងប្រវត្តិសាស្ត្រឱ្យជនយុគសម័យថ្មីបានដឹង។**



Photo: Chen Chanratana

សកម្មភាពរបស់និស្សិតក្នុងពេលធ្វើកំណាយនៅស្ថានីយបុរាណវិទ្យាភូមិ១៨ ស្រុកមេមត់ កំពង់ចាម

## ការងារ

ការងាររបស់អ្នកបុរាណវិទ្យាមានច្រើន ប៉ុន្តែ ជាសំខាន់គឺធ្វើកំណាយជីករុករកសំណល់ដែលនៅក្រោមដី មានដូចជា ឆ្អឹងមនុស្ស ឆ្អឹងសត្វ ឬវត្ថុប្រើប្រាស់ផ្សេងៗរបស់មនុស្ស។ល។ គេយកសំណល់អស់ទាំងនោះ មកធ្វើការវិភាគតាមបែបបុរាណវិទ្យាដើម្បីស្វែងយល់អំពីឫសគល់ ឬប្រវត្តិកាលបរិច្ឆេទរបស់ពួកវា ក្នុងគោលបំណងសិក្សាអំពីជីវភាពរស់នៅរបស់មនុស្សក្នុងសម័យបុរាណកាល។ ម្យ៉ាងវិញទៀត អ្នកបុរាណវិទ្យាអាចស្រាវជ្រាវខាងផ្នែកប្រវត្តិសាស្ត្រ និងផ្នែកសិក្សាសង្គមផងដែរ ពោលគឺសិក្សាទៅលើទំនៀមទំលាប់ប្រពៃណីរបស់ប្រជាជនក្នុងបច្ចុប្បន្នភាព ក៏ដូចជាក្នុងសម័យបុរាណ។ លោក ចិន ច័ន្ទរតនា និស្សិតបុរាណវិទ្យា និយាយថា: "ការងារអ្នកបុរាណវិទ្យា ត្រូវឱ្យមានភាពហ្មត់ចត់ និងសុខភាពរឹងមាំ។ យើងត្រូវទៅធ្វើការសិក្សាដល់ទីកន្លែងផ្ទាល់ៗ ដូចជាតាមស្ថានីយកំណាយ និងបូជនីយដ្ឋានប្រវត្តិសាស្ត្រនានា ទោះបីពេលខ្លះត្រូវលុកព្រៃ ឬត្រូវឡើងភ្នំក្តី"។

## ផលតបស្នង

ក្នុងមុខអាជីពជាអ្នកបុរាណវិទ្យា និស្សិតដែលទើបនឹងរៀនចប់ហើយមកធ្វើការងារ គេអាចទទួលបានប្រាក់ខែ ពី១២០ ដុល្លារទៅដល់២៥០ដុល្លារ។ បើសិនគេធ្វើការងារបានរយៈពេលយូរ ប្រាក់ខែនឹងកើនឡើង ប៉ុន្តែច្រើនឬតិចគឺអាស្រ័យទៅលើគុណភាពប្រសិទ្ធិភាពនៃការងាររបស់គេ និងគោលនយោបាយប្រាក់បៀវត្សរបស់ស្ថាប័នឬអង្គការដែលពួកគេធ្វើការឱ្យដែលភាគច្រើនមានទីតាំងនៅខេត្តសៀមរាប។

## ព័ត៌មានសិក្សា

ដើម្បីក្លាយខ្លួនជាអ្នកបុរាណវិទ្យា យើងអាចទៅសិក្សានៅមហាវិទ្យាល័យបុរាណវិទ្យា រាជធានីភ្នំពេញ។ ការសិក្សាគឺមានរយៈពេល៤ឆ្នាំ។ មហាវិទ្យាល័យបុរាណវិទ្យាគឺអាចទទួលសិស្សដែលទើបនឹងប្រលងជាប់ថ្នាក់ទី១២ ឱ្យចូលរៀន ក្រោយពីធ្វើការប្រលងសំរាំងជ្រើសរើស។ សិស្សត្រូវប្រលងលើមុខវិជ្ជា២ គឺវប្បធម៌ទូទៅ និងគំនូរមើលឃើញ។

ផាត សំភី

## មហាវិទ្យាល័យបុរាណវិទ្យា

គឺជាមហាវិទ្យាមួយក្នុងចំណោមមហាវិទ្យាល័យទាំងប្រាំនៃសកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ដែលក្នុងនោះរួមមានមហាវិទ្យាល័យបុរាណវិទ្យា មហាវិទ្យាល័យស្ថាបត្យកម្ម និងនគររូបនីយកម្ម មហាវិទ្យាល័យតូរតន្ត្រី មហាវិទ្យាល័យនាដសាស្ត្រ ហើយចុងក្រោយ គឺមហាវិទ្យាល័យសូនរូប។ ទំនាក់ទំនងតាមលេខទូរស័ព្ទ: ០២៣ ៤២៦ ២៨៩។

## ទស្សនៈ

# ប្រជាធិបតេយ្យមានសង្គមបើកចំហ

**ប្រិយមិត្តបានយល់រួចមកហើយអំពីប្រវត្តិ និងនិយមន័យរបស់លទ្ធិប្រជាធិបតេយ្យ។ ពេលនេះ អ្នកនាំសារនឹងបង្ហាញជូននូវគោលគំនិតរបស់លទ្ធិនេះវិញម្តង។**

គោលគំនិតលទ្ធិប្រជាធិបតេយ្យ

គំនិតក្នុងលទ្ធិប្រជាធិបតេយ្យបានសម្តែងថា គេត្រូវតែបោះបង់ចោលអំពើហិង្សាដែលមានប្រភពមកពីកិច្ចពិភាក្សានយោបាយ។ នៅក្នុងដំណើរការរបស់ខ្លួនលទ្ធិប្រជាធិបតេយ្យគឺអាស្រ័យលើការផ្ទេរអំណាចដែលគួរឱ្យទុកចិត្តពីសំណាក់ប្រជាពលរដ្ឋទៅឱ្យអ្នកតំណាងរបស់ពួកគេដែលជាតំណាងរាស្ត្រ។ តំណាងរាស្ត្រធ្វើការនៅខាងក្នុង ឬខាងក្រៅប្រទេសរបស់ខ្លួនក្នុងនាមប្រជាពលរដ្ឋខ្លួន និងស្វែងរកផលប្រយោជន៍ ឱ្យប្រជាពលរដ្ឋខ្លួន។ ការគោរពនូវមតិសាធារណៈ និងផលប្រយោជន៍ទូទៅរបស់ប្រទេសគឺជាទង្វើដែលទាំងអស់គ្នាត្រូវតែធ្វើ។ នេះគឺជាវប្បធម៌នៃលទ្ធិប្រជាធិបតេយ្យ។

នៅក្នុងលទ្ធិប្រជាធិបតេយ្យ បុគ្គលម្នាក់ ក្រុមមួយ បក្សសម្ព័ន្ធមួយ ទោះបីឈ្នះឆ្នោតក្តី គឺមិនអាចឆក់យកនូវអធិបតេយ្យ និងអំណាចមកគ្រប់គ្រងម្នាក់ឯងបានឡើយ។

ប្រទេសប្រជាធិបតេយ្យគឺមានសង្គមបើកចំហ "មានអរិយធម៌" មានន័យថា នៅក្នុងសង្គមនោះតែងមានប្រពៃណីព្រួយបារម្ភចំពោះផលប្រយោជន៍សាធារណៈ ឬយ៉ាងហោច

# ល្ខោនស្បែករបស់ខ្មែរ

**ល្ខោនស្បែកជាទម្រង់សិល្បៈមួយរបស់ខ្មែរដែលបានកើតឡើងតាំងពីមុនសម័យអង្គរ។ នេះគឺជាសិល្បៈមួយដែលមានភាពស៊ាំញ៉ាំក្នុងការសម្តែង។ សព្វថ្ងៃ អ្នកចេះដឹងសិល្បៈនេះនៅមានការខ្វះខាត។**

ល្ខោនស្បែករបស់ខ្មែរមានបីប្រភេទ ដែលនៅក្នុងនោះមានស្បែកធំ ស្បែកតូច និងស្បែកពណ៌។ ល្ខោនទាំងបីទំរង់នេះមានរបៀប និងលក្ខណៈសម្តែងខុសៗពីគ្នា។ ស្បែកធំគឺជាប្រភេទល្ខោនមួយដែលលេងបានតែរឿងមួយ គឺរឿង “រាមកេរ្តិ៍”។ ហើយសម្តែងបានតែនៅក្នុងវត្ត រាជវាំង និងនៅក្នុងប្រាសាទ។ កញ្ញា Delphine ជាអ្នកគ្រប់គ្រងនៅសមាគមសិល្បៈខ្មែរសុវណ្ណភូមិបានប្រាប់ឱ្យដឹងថាៈ ”ការសម្តែងល្ខោនស្បែកធំនេះមានរយៈពេល ៧យប់ ៧ថ្ងៃ ហើយអ្នកសម្តែងមានគ្នាពី៦០-១០០នាក់។ ដូច្នេះទើបពេលបច្ចុប្បន្ននេះ ពុំសូវមានការសម្តែងល្ខោនស្បែកធំនេះ”។ ចំពោះស្បែកតូចមានលក្ខណៈខុសគ្នាពីស្បែកធំដោយតម្រូវឱ្យសម្តែងបានតែនៅតាមទីសាធារណៈហើយអាចសម្តែងបានចំពោះរឿងខ្លីៗដូចជារឿងសព្វសិទ្ធជាដើម។ ជាទូទៅ ល្ខោនស្បែកសម្តែងនៅពេលយប់ព្រោះល្ខោននេះគេយកស្រមោលធ្វើជារឿង។ ដោយឡែក ល្ខោនស្បែកពណ៌គឺសម្តែងនៅពេលថ្ងៃ ដោយសារវាមានពណ៌សំរាប់បង្ហាញជូនអ្នកទស្សនា។ ចំពោះស្បែកដែលគេយកមកធ្វើជារូបនោះ គឺជាស្បែកគោ ឬស្បែកខ្លាឃ្មុំដែលងាប់ដោយខ្លួនឯង។ ការសម្តែងល្ខោនស្បែកធំ អ្នកលេងអាចចេញមកសម្តែងនៅខាងក្រៅអេក្រង់បាន ហើយអ្នកនោះក៏ត្រូវបានតម្រូវឱ្យច្រៀង និងនិយាយដោយខ្លួនឯងផ្ទាល់ដែរ។ ផ្ទុយពីនេះ ល្ខោនស្បែកតូច អ្នកសម្តែង អ្នកច្រៀង អ្នកនិយាយ គឺខុសគ្នា ហើយតម្រូវការមនុស្សតែ១០នាក់ប៉ុណ្ណោះក្នុងមួយរឿង។ នៅមុនពេលសម្តែងមានការរៀបចំសែនព្រេនរំលឹកដល់គ្រូឥសីដើម្បីឱ្យគាត់ជួយ ឱ្យការសម្តែងត្រូវបានគេចាប់អារម្មណ៍ និងមានភាពរស់រវើក។
តាមការស្រាវជ្រាវបង្ហាញថា ល្ខោនស្បែកធំមានប្រភពមកពីខេត្តសៀមរាប និងស្បែកតូចមកពីខេត្តបាត់ដំបង។
ទូរស័ព្ទៈ ០១២ ៨៤៦០២០ មុំ គន្ធា


Photo: Sovanaphum

ទស្សនីយភាពនៃការសម្តែងល្ខោនស្រមោលស្បែកធំរបស់សមាគមសិល្បៈខ្មែរសុវណ្ណភូមិ

## ល្ខោនស្បែកលើឆាកអន្តរជាតិ

**សមាគមសុវណ្ណភូមិធ្លាប់បាននាំយកល្ខោនស្បែកខ្មែរទៅសម្តែងនៅប្រទេសជាច្រើន។ តួយ៉ាងនៅដើមឆ្នាំ២០០៥នេះ សំរាប់ការសម្តែងនៅទីក្រុងឈៀងម៉ៃដែលមាន៦ប្រទេសមកចូលរួម ល្ខោនស្បែកខ្មែរយើងទទួលបានជោគជ័យយ៉ាងខ្លាំងដោយមានការគាំទ្រច្រើនពីអ្នកទស្សនា។**

ណាស់ផលប្រយោជន៍របស់ប្រជាពលរដ្ឋ ឬប្រជាជនភាគច្រើន មានជាអាទិ៍ ធ្វើការដោះស្រាយបញ្ហានៃភាពក្រីក្រ សុខភាព និងការអប់រំជាដើម។ល។ និង។ល។ គេត្រូវធ្វើការខិតខំប្រឹងប្រែងដ៏ពិតប្រាកដមួយក្នុងការដឹកនាំដើម្បីផលប្រយោជន៍ទូទៅរបស់ប្រជាពលរដ្ឋដោយជំរុញឱ្យប្រជាពលរដ្ឋខ្លួនឯងចូលរួមក្នុងសកម្មភាពនៃការខិតខំប្រឹងប្រែងនេះ ទោះបីពួកគេធ្វើឡើងដោយប្រយោលក្តី។
លទ្ធិប្រជាធិបតេយ្យ គឺជាសិទ្ធិជាសេរីភាព និងជាមធ្យោបាយពិតប្រាកដដើម្បីធ្វើអ្វីៗជាវិជ្ជមានដើម្បីផលប្រយោជន៍ខ្លួនឯង និងសង្គមដែលគេរស់នៅ ដោយមិនបំផ្លាញអ្នកដទៃទោះអ្នកនោះនៅជិតក្តី ឬឆ្ងាយក្តី។
លទ្ធិប្រជាធិបតេយ្យ គឺជាការជជែកគ្នា ការពិភាក្សាគ្នាជាមួយ ហើយសេចក្តីសំរេចចុងក្រោយត្រូវតែជាលទ្ធផលនៃកិច្ចជជែកពិភាក្សាទាំងនេះ។
អ្នកដឹកនាំត្រូវតែគិតគូរដល់តំរូវការក្តីប្រាថ្នា ឬបញ្ហារបស់ប្រជាពលរដ្ឋ ឱ្យបានច្រើនបំផុតតាមដែលអាចធ្វើទៅបាន។
លទ្ធិប្រជាធិបតេយ្យមិនគ្រាន់តែជារូបផ្តុំផ្តុំរបស់គណៈបក្សនយោបាយ ការបង្កើតនីតិរដ្ឋ ឬមួយក៏ជាការបោះឆ្នោតប៉ុណ្ណោះនោះទេ គឺទាំងអស់នេះត្រូវស្ថិតនៅជាមួយគ្នាក្នុងពេលតែមួយដោយមិនអាចកាត់ផ្តាច់ពីគ្នាបាន។ បើនិយាយឱ្យលើសពីនេះ គឺអ្វីៗទាំងអស់ត្រូវស្ថិតនៅជាមួយគ្នា។

P.R

## ប្រជាធិបតេយ្យនៅកម្ពុជា

**គឺជារបបប្រជាធិបតេយ្យសេរីពហុបក្ស។ ប្រជាពលរដ្ឋប្រើអំណាចតាមរយៈរដ្ឋសភា ព្រឹទ្ធសភា រាជរដ្ឋាភិបាល និងសាលាជំរះក្តី។ អំណាចបែងចែកដាច់ពីគ្នារវាងអំណាចនីតិបញ្ញត្តិ នីតិ-ប្រតិបត្តិ និងតុលាការ។**



ទីនេះគឺជារាជាណាចក្ររបស់សត្វកំប្រុក។ ពួកវាកំពុងតែស្វែងរកចំណីអាហារ នៅគ្រប់ទីកន្លែង។ ដូច្នេះ សូមធ្វើការទស្សន៍ទាយទៅមើល តើមានសត្វកំប្រុកទាំងអស់ប៉ុន្មានដែលកំពុងតែស្វែងរកចំណីនៅក្នុងព្រៃស្តុកនេះ?

គំនូរ : ក.

ការិយាល័យផ្សព្វផ្សាយព័ត៌មានព្រះសហគមន៍កាតូលិក ផ្ទះលេខ ២៥ ផ្លូវលេខ ២៤២ សង្កាត់ បឹងព្រលិត រាជធានី ភ្នំពេញ
Tel/Fax: (855) 23 224 120 E-mail: csc@catholiccambodia.org
អភិបាលគ្រប់គ្រង: លោកអភិបាល អេមីល ដេតម្ប អគ្គនាយក: លោកបូជាចារ្យ អូមែរ ហ្សីរ៉ាល់ដូ